# ការដាក់ពាក្យ ស្នើសុំហិរញ្ញប្បទាន

សូមអញ្ជើញមកកាន់សាខាណាមួយ
របស់ធនាគារយើងខ្ញុំ ឬទំនាក់ទំនងមកកាន់
ទូរស័ព្ទលេខ 096 811 1118

មន្រ្តីជំនាញនឹងប្រឹក្សាយោបល់ហើយ
ជួយរៀបចំសំណើសុំហិរញ្ញប្បទានជូនលោកអ្នក

ឬ

អាចចុះឈ្មោះស្នើសុំហិរញ្ញប្បទានតាមរយៈអនឡាញ
ដោយគ្រាន់តែចូលទៅកាន់៖
www.smebankcambodia.com.kh

*លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្តន៍
*ធនាគាររក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌនានា
ដោយពុំចាំបាច់ជូនដំណឹងជាមុន។

## ការិយាល័យទំនាក់ទំនងអតិថិជន

**096 811 1118**

Scan above QR code
to follow our Social Media


info@smebankcambodia.com.kh
smebankcambodia.com.kh





# គម្រោងហិរញ្ញប្បទាន សហគ្រាសធុនតូច (CMES)




# គម្រោងហិរញ្ញប្បទាន សហគ្រាសធុនតូច

**គម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច** ជាគម្រោងហិរញ្ញប្បទានគ្មានទ្រព្យធានា ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់ការគាំទ្រដល់ម្ចាស់សហគ្រាសធុនតូចទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈគម្រោងហិរញ្ញប្បទានដែលមានលក្ខខណ្ឌអនុគ្រោះ អត្រាការប្រាក់ទាប។

## អត្ថប្រយោជន៍

- ផ្តល់ជូននូវអត្រាការប្រាក់ដែលមានភាពប្រកួតប្រជែង
- គម្រោងហិរញ្ញប្បទានដែលមានរយៈពេលវែង
- មិនតម្រូវមានទ្រព្យធានា
- បង្កើនប្រសិទ្ធភាព និងផលិតភាពអាជីវកម្ម

## លក្ខណៈពិសេស

- **ទំហំហិរញ្ញប្បទាន៖** រហូតដល់ ២០០ លានរៀល ឬ ៥០,០០០ ដុល្លារអាមេរិក
- **រូបិយប័ណ្ណ៖** ប្រាក់រៀល ឬ ប្រាក់ដុល្លារអាមេរិក
- **គោលបំណង៖** ប្រើប្រាស់ជាទុនបង្វិល ឬទុនវិនិយោគ
- **អត្រាការប្រាក់ប្រចាំឆ្នាំ៖** ៧.៥០% សម្រាប់សហគ្រាសចុះបញ្ជី ដែលស្ថិតក្នុងវិស័យអទិភាព និង ៨.៥០% សម្រាប់សហគ្រាសទូទៅ ឬសហគ្រាសមិនទាន់ចុះបញ្ជី
- **រយៈពេលហិរញ្ញប្បទាន៖** រហូតដល់ ៥ឆ្នាំសម្រាប់ទុនបង្វិល ឬ ៧ឆ្នាំសម្រាប់ទុនវិនិយោគ
- **ទ្រព្យធានា៖** មិនតម្រូវមានទ្រព្យធានា

## ឯកសារតម្រូវ

- ឯកសារបញ្ជាក់អត្តសញ្ញាណភាគីអ្នកខ្ចី រួមមាន អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬ លិខិតដែលមានតម្លៃស្មើ
- ឯកសារអាជីវកម្ម រួមមាន អាជ្ញាបណ្ណអាជីវកម្ម ប័ណ្ណប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជី (ប្រសិនបើមាន)
- ឯកសារបញ្ជាក់ចំណូលចំណាយ (ប្រសិនបើមាន)
- របាយការណ៍ហិរញ្ញវត្ថុ (ប្រសិនបើមាន)
- របាយការណ៍ធនាគារ (ប្រសិនបើមាន)
- ឬឯកសារផ្សេងៗទៀត អាស្រ័យទៅតាមប្រភេទអាជីវកម្ម

## លក្ខណៈវិនិច្ឆ័យ

- តម្រូវមានពិន្ទុក្នុងការវាយតម្លៃប្រវត្តិឥណទានចាប់ពី ១,០០០ពិន្ទុឡើងទៅ
- សហគ្រាសធុនតូចដែលស្ថិតក្នុងប្រទេសកម្ពុជា
- សហគ្រាសធុនតូច ដែលមានម្ចាស់ភាគហ៊ុនជាជនជាតិខ្មែរ យ៉ាងហោច ៥១%
- សហគ្រាសធុនតូច ដែលស្ថិតក្នុងវិស័យអាទិភាព និងបានចុះបញ្ជីអាជីវកម្ម ត្រូវបានលើកទឹកចិត្ត

